# Living the Lotus

*Buddhism in Everyday Life*

8
2024
VOL. 227





## Leaders in North America Study the Lotus Sutra with Dr. Dominick Scarangello, Translator of the Revised Edition of *Buddhism for Today,* Revised Edition, at the Los Angeles Dharma Center





Living the Lotus
Vol. 227 (August 2024)

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp


រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

*President's Message*

# យើងទាំងឡាយសុទ្ធតែវិលត្រឡប់ ទៅ "ស្រុកកំណើត" វិញ

ព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ



## អនិច្ចធម្មនៃព្រះស្ថាបនិកកៃសូសាម៉ា

នៅក្នុងគម្ពីរព្រះពុទ្ធសាសនាដែលមានចំណា ស់ជាងគេបំផុតគឺ "គម្ពីរសិត្តបិដក" ដែលផ្សព្វផ្សាយឧត្តមគតិព្រះពុទ្ធ មានកំណាព្យមួយដែលមានចំណងជើងថា "នាយបាវ៉ាដ បាជាអ្នកភ្ជួររាស់ស្រែ" ។ នៅក្នុងកំណាព្យនោះ មានព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធជាមួយនឹងព្រាហ្មណ៍ ។ខ្ញុំព្រះករុណាអាត្មាភាពបានលើកយកកំណាព្យនោះទៅចុះក្នុងសៀវភៅដែលខ្ញុំព្រះករុណាអាត្មាភាពបានសរសេរគឺសៀវភៅដែលមានចំណងជើងថា "ភ្ជួររាស់ស្រែដួងចិត្ត"។

ឆ្នាំ២០២៤នេះក្នុងទំព័រនេះយើងទាំងអស់គ្នាបាននាំគ្នាត្រិះរិះគិតពីវិធីសាស្ត្រព្យាយាមក្នុងការប្រតិបត្តិព្រះធម៌និងរបៀបរៀបចំចិត្ត ដោយយកកំណាព្យនោះមកធ្វើជាមេរៀនគោល។នៅទីកបញ្ចប់នៃកំណាព្យមានឃ្លាមួយចែងថា៖ "ការភ្ជួររាស់គឺគេធ្វើបែបនេះ ហើយនឹងបានទទួលផ្លែផ្កាជាជីវិតអមតៈ" ។ដើរតាមលំហូនោះកាលពីខែមុន នៅពេលដែលខ្ញុំព្រះករុណាអាត្មាភាពលើកយកប្រធានបទជីវិតរបស់មនុស្សមកនិយាយ ចុងក្រោយគេនោះខ្ញុំព្រះករុណាអាត្មាភាពបានតណ្តឹងសួរទៅអ្នកទាំងអស់គ្នាថាតើ "អមតៈ" ឬមិនស្លាប់នោះមានន័យដូចម្តេច?ឆ្លើយតបទៅនឹងសំណួរនេះដំបូងឡើងខ្ញុំព្រះករុណាអាត្មាភាពសូម

អធិប្បាយពីគំនិតដ៏ស្មោះត្រង់របស់ខ្ញុំព្រះករុណាអាត្មាភាពទៅលើមរណភាព

សិន។មុននឹងចូលទៅដល់សាច់រឿងសូមអនុញ្ញាតិឱ្យខ្ញុំព្រះករុណាអាត្មាភាពនិយាយពីពេលចុងក្រោយបង្អស់ដែលខ្ញុំព្រះករុណាអាត្មាភាពមានជាមួយនឹងព្រះគ្រូស្ថាបនិកកៃសូសាម៉ាសិន។

នៅថ្ងៃទី៤ខែតុលាឆ្នាំ១៩៩៩វេលាម៉ោង១០និង៣៤នាទីព្រឹកព្រះគ្រូស្ថាបនិកសមាគមរីហ្សូកូសេកៃ កៃសូសាម៉ា នីវ៉ាណូ នីកយេ ដែលត្រូវជាឪពុកនិងគ្រូរបស់ខ្ញុំព្រះករុណាអាត្មាភាពបានទទួលអនិច្ចធម្ម បញ្ចប់ឆាកជីវិតរបស់លោក។ព្រះគ្រូស្ថាបនិកលោកបិទព្រះនេត្រចេញដំណើរទៅយ៉ាងស្ងៀមស្ងាត់ក្រោមក្រសែភ្នែកបងប្អូននិងក្រុមគ្រួសារដែលមកប្រជុំគ្នានៅជុំវិញគ្រែដំណេករបស់លោកនិងបរិស័ទទាំងឡាយដែលកំពុងតែតាមដានស្ថានភាពរបស់លោកពីចម្ងាយ។

មុនពេលដែលព្រះអង្គលោកផុតដង្ហើមហើយបិទព្រះនេត្រទាំងសងខាងនោះ ខ្ញុំព្រះករុ ណាអាត្មាភាពបានកាន់ព្រះហស្ថ (ដៃ) ស្តាំរបស់លោក។ កៃសូសាម៉ាលោកខំបើកព្រះនេត្រគ្រលៀសមើលយើងទាំងឡាយម្នាក់ៗ ដែលឈរជុំវិញគ្រែព្រះអង្គឃឹតៗហាក់ដូចជាចង់ប្រាប់ថាលោកលាហើយ បន្ទាប់មកព្រះអង្គក៏បិទព្រះនេត្រទៅវិញទៅ ។នោះគឺមួយប៉ប្រិចដែលកៃសូសាម៉ាលោកលាចាកពីលោកនេះទៅ។

## ចាប់ផ្តើមពីកិច្ចប្រតិបត្តិរៀងៗអាយឆ្ពោះទៅរកបញ្ហានៃពិភពលោក

ស្រុកកំណើត／ ពីទីនោះយើងចាកចេញមក／ ស្រុកកំណើត／ទីនោះហើយដែលយើងត្រឡប់ទៅវិញ (កវីតូយ យោស៊ីអូ)។ គឺជាកំណាព្យដែលខ្ញុំព្រះករុ ណាអាត្មាភាពស្រឡាញ់ហើយទន្ទេញចាំមាត់ពីយូរយារណាស់មកហើយ។ពីខែមុនដូចដែលខ្ញុំព្រះករុណាអាត្មាភាពបានអធិប្បាយរួចមកហើយថាឆាកជីវិតរបស់យើងម្នាក់ៗ ប្រៀបដូចជា

មហាទន្លេដែលបន្តហូរមិនឈប់ ជានិរន្តន៍ពីអតីតកាលទៅរកអនាគតកាលគឺទៅរក “ស្រុកកំណើត” ដែលជា “មហាជីវិត” ដ៏ធំ

វិញ។ប្រសិនបើយើងគិតបែបនេះយើងក៏លែងសូវមានសេចក្តីបារម្ភឬភ័យខ្លាចមរណភាពពេកទៀតដែរ។

ប្រសិនបើឱ្យនិយាយរៀបរាប់បន្តិចទៀតពីខ្ញុំព្រះករុណាអាត្មាភាពវិញ ការដែលបានឈរមើលការលាចាកលោកនៃព្រះស្ថាបនិកកៃសូសាម៉ានាំឱ្យខ្ញុំព្រះករុណាអាត្មាភាពមានអារម្មណ៍ថាអាចទទួលយកមរណភាពបានដោយចិត្តស្ងប់គឺឱ្យអាចគិតថា៖“ឱបើបានស្លាប់បែបនេះមិនដឹងជាល្អយ៉ាងណាទេ”។

គឺថាមរណភាពឬពេលចុងក្រោយនៃជីវិតរបស់កៃសូសាម៉ាគឺជាឧត្តមគតិដែលមានន័យថាខ្ញុំព្រះករុណាអាត្មាភាពអាចជម្នះនូវការភ័យខ្លាចស្លាប់ឬក៏បានផ្តល់ដល់ខ្ញុំព្រះករុណាអាត្មាភាពនូវ “ផ្លែផ្កានៃជីវិតអមតៈ” ។

“ជីវិតអមតៈ” មិនមែនមានន័យថាមិនស្លាប់ទេ ។ ដែលហៅថាជីវិតអមតៈគឺបេះដូងដែលបានត្រូវបានដោះលែងឱ្យរួចផុតចាកពីទុក្ខដែលបណ្តាលមកពីការចង់រស់នៅរហូតជានិច្ចជាកាលដែលជាសេចក្តីប្រាថ្នាមួយប៉ប្រិចឱ្យចិត្តបានធូរស្រាល។នេះបើតាមដែលខ្ញុំព្រះករុណាអាត្មាភាពបកស្រាយពាក្យថា “ជីវិតអ មតៈ មិនស្លាប់ ឬក៏ ផ្លែផ្កានៃជីវិតអមតៈ”។

បន្ទាប់មកយោងទៅតាមការសិក្សាព្រះធម៌ដែលជាការប្រៀនប្រដៅរបស់ព្រះសម្មា សម្ពុទ្ធយើងអាចចាប់យក “ផ្លែផ្កានៃជីវិតអមតៈ” បាន។ទី១គឺត្រូវឆ្លាក់ជាប់ក្នុងបេះដូងនូវ ព្រះធម៌អនិច្ចំ គឺការបង្រៀនថាអ្វីៗសុទ្ធតែមិនទៀងហើយជម្នះលើមរណភាពបាន។ត្រូវយល់ដឹងថាមរណភាពក៏ជាលំហូមួយនៃធម្មជាតិដែលកើតហើយតែងតែវិនាសប្រែប្រួល

ម្យ៉ាងទៀតនៅក្នុងគម្ពីរព្រះបទុមសូត្រមានចែងថា “ព្រះពុទ្ធមានជីវិតអមតៈ” ។ប្រសិនបើយើងឈរលើការយល់ឃើញឬទស្សនៈនេះយើងនឹងមានភាពកក់ក្តៅក្នុងចិត្តដោយយើងដែលជាធាតុព្រះពុទ្ធស្រេចទៅហើយនោះទោះជាស្លាប់ទៅក៏នឹងចូលទៅផ្តុំផ្សំទៅជា “មហាជីវិតដ៏ធំមួយ” នៃព្រះពុទ្ធហើយនឹងរស់នៅជានិច្ចនិរន្តន៍ជាអមតៈ។លើសពីនេះទៅទៀត គម្ពីរធម្មបទកថាបានបង្រៀនថាកិច្ចប្រតិបត្តិជានិច្ចជាកាលនាំឱ្យបានទៅដល់ទី “អមតៈគឺជីវិតមិនស្លាប់” ។សេចក្តីព្យាយាមនៅក្នុងជីវភាពរាល់ថ្ងៃ ទោះបីជាការងារតូចតាចមួយក្តីបើយើងធ្វើដោយផ្ចិតផ្ចង់បន្តិចម្តងៗទៅ យោលទៅតាមទ្រឹស្តី “ច្រវាក់នៃកម្មផលដ៏ច្រើន ឥទ្ធិពលនោះនឹងផ្សព្វផ្សាយទូលំទូលាយគ្មានព្រំដែនកំណត់ជាអមតៈ” ។(វិទូ ណាកាមូរ៉ា ហាជីមុ)។

ពោលគឺថាទង្វើដែលយើងទាំងអស់គ្នាកំពុងតែប្រតិបត្តិមានទង្វើព្រះពោធិសត្វជាអាទិ៍បានផ្សាយឥទ្ធិពលទៅគ្រប់ទីកន្លែងនិងគ្មានកាលកំណត់ជាបន្តបន្ទាប់។ម្យ៉ាងទៀតទង្វើជាគម្រូនេះទោះបីជាសាម៉ីខ្លួនបានស្លាប់ទៅហើយក្តីក៏នឹងនៅរស់រវើកជានិច្ចនៅក្នុងចិត្តរបស់មនុស្សម្នាទាំងឡាយ។នេះក៏ជារូបរាងមួយនៃ “ជីវិតអមតៈ” ដែរ។

ដោយកុសលផលបុណ្យ ខ្ញុំព្រះករុណាអាត្មាភាពអាចរស់រានមានជីវិតលើសព្រះជន្មាយុដែលព្រះសម្មាសម្ពុទ្ធទ្រង់ចូលបរិនិព្វាន៦ឆ្នាំហើយមានភ័ព្វសំណាងដោយបានឃើញមរណភាពនៃកៃសូសាម៉ានិងក្រេបរសជាតិ “ផ្លែផ្កានៃជីវិតអមតៈ” អាចយល់និងអាចនិយាយយ៉ាងក្បោះក្បាយជាមួយអ្នកទាំងអស់គ្នាថា “យើងអាចត្រឡប់ទៅស្រុកកំណើតយើងវិញអង្កាល់ក៏បាន” ។

From *Kosei*, August 2024

# Rissho Kosei-kai International

## Make Every Encounter Matter




## A Global Buddhist Movement




**Information about local Dharma centers**

**facebook**

**X**

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp